# ច្បាប់

# ស្តីពី

# លក្ខន្តិកៈទូទៅចំពោះយោធិន
# នៃកងយោធពលខេមរភូមិន្ទ

ជស/រកម/១១៩៧/០៥

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិវង្ស អគ្គមហាបុរសរតនៈ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * * * * * * *

រដ្ឋសភា
លេខ [illegible]
ថ្ងៃទី [illegible] ម៉ោង [illegible]
បញ្ជូនទៅ [illegible]

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងការពារជាតិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពី លក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កងយោធពលខេមរភូមិន្ទមានភារកិច្ចបម្រើប្រទេសជាតិ។ បេសកកម្មរបស់កងយោធពលខេមរភូមិន្ទគឺត្រូវរៀបចំប្រើប្រាស់កម្លាំងកងយោធពលខេមរភូមិន្ទដើម្បីការពារ កសាងមាតុភូមិ និងដើម្បីផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ប្រទេសជាតិ ។

ក្នុងកាលៈទេសៈចាំបាច់ កងយោធពលខេមរភូមិន្ទនឹងអាចចូលរួមក្នុងការការពារសន្តិសុខសាធារណៈនិងជាជំនួយដល់ប្រជាពលរដ្ឋ ដែលជួបការលំបាកឬមានអាសន្នមហន្តរាយ ។

យោធិនត្រូវគោរពវិន័យយ៉ាងម៉ឺងម៉ាត់ ភក្តីភាពនិងក្លាហានហ៊ានធ្វើពលិកម្មនៅគ្រប់កាលៈទេសៈទាំងអស់ចំពោះជាតិមាតុភូមិ ។

យោធិនត្រូវបំពេញករណីយកិច្ចជាចាំបាច់ ដើម្បីសក្តិសមទៅនឹងការគោរពស្រឡាញ់ពីសំណាក់ប្រជាពលរដ្ឋ ។

លក្ខន្តិកៈទូទៅនេះធានាសិទ្ធិ សេរីភាពនិងចែងអំពីកាតព្វកិច្ចចំពោះយោធិនគ្រប់រូបរួមមាន :

១-យោធិនអាជីព

២-យោធិនជាប់កិច្ចសន្យា

**មាត្រា ២.-**

យោធិនទាំងឡាយត្រូវស្ថិតនៅក្នុងបទប្បញ្ញត្តិរបស់លក្ខន្តិកៈទូទៅនេះ ។

ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតដើម្បីពិនិត្យបទដ្ឋានច្បាប់ទាំងឡាយដែលទាក់ទងទៅនឹងបញ្ហាយោធា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

បទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣.-**

កងយោធពលខេមរភូមិន្ទមានកងទ័ពបីប្រភេទ :

១-កងទ័ពជើងគោក

២-កងទ័ពជើងអាកាស

៣-កងទ័ពជើងទឹក

**មាត្រា ៤.-**

ឋានានុក្រមរបស់កងយោធពលខេមរភូមិន្ទមាន ៣ថ្នាក់ :

១-ពលទាហាន

២-នាយទាហានរង

៣-នាយទាហាន

**មាត្រា ៥.-**

នៅក្នុងលំដាប់ថ្នាក់ឋានន្តរស័ក្តិយោធិនទូទៅមាន :

**១-ឋានន្តរស័ក្តិពលទាហានមាន :**

| កងទ័ពជើងគោកនិងកងទ័ពជើងអាកាស | កងទ័ពជើងទឹក |
|---|---|
| -ពលទោ | -នាវិកទោ |
| -ពលឯក | -នាវិកឯក |
| -នាយទោ | -ចក្រពាលរងទោ |
| -នាយឯក | -ចក្រពាលរងឯក |

**២- ឋានន្តរស័ក្តិនាយទាហានរងមាន :**

| កងទ័ពជើងគោកនិងកងទ័ពជើងអាកាស | កងទ័ពជើងទឹក |
|---|---|
| -ពលបាលត្រី | -ចក្រពាលត្រី |
| -ពលបាលទោ | -ចក្រពាលទោ |
| -ពលបាលឯក | -ចក្រពាលឯក |
| -ព្រិន្ទបាលទោ | -នាយចក្រពាលទោ |
| -ព្រិន្ទបាលឯក | -នាយចក្រពាលឯក |

## ៣.- ឋានន្តរសក្តិនាយទាហានមាន :

### ៣.១.-នាយទាហានថ្នាក់អនុសេនីយ៍មាន :

| កងទ័ពជើងគោកនិងកងទ័ពជើងអាកាស | កងទ័ពជើងទឹក |
|---|---|
| -នាយកំណាន់ | -នាយនាវីកំណាន់ |
| -អនុសេនីយ៍ត្រី | -អនុនាវីត្រី |
| -អនុសេនីយ៍ទោ | -អនុនាវីទោ |
| -អនុសេនីយ៍ឯក | -អនុនាវីឯក |

### ៣.២.-នាយទាហានថ្នាក់វរសេនីយ៍មាន :

| កងទ័ពជើងគោកនិងកងទ័ពជើងអាកាស | កងទ័ពជើងទឹក |
|---|---|
| -វរសេនីយ៍ត្រី | -វរនាវីត្រី |
| -វរសេនីយ៍ទោ | -វរនាវីទោ |
| -វរសេនីយ៍ឯក | -វរនាវីឯក |

### ៣.៣.-នាយទាហានថ្នាក់ឧត្តមសេនីយ៍មាន :

| កងទ័ពជើងគោកនិងកងទ័ពជើងអាកាស | កងទ័ពជើងទឹក |
|---|---|
| -ឧត្តមសេនីយ៍ត្រី | -ឧត្តមនាវីត្រី |
| -ឧត្តមសេនីយ៍ទោ | -ឧត្តមនាវីទោ |
| -ឧត្តមសេនីយ៍ឯក | -ឧត្តមនាវីឯក |
| -នាយឧត្តមសេនីយ៍ | -នាយឧត្តមនាវី |
| -ឧត្តមសេនីយ៍ផុតលេខ | |

## មាត្រា ៦.-

យោធិនស្ថិតនៅក្នុងអង្គធំៗពីរ :

-អង្គទី ១ : ប្រមូលផ្តុំយោធិននៃកងទ័ពជើងគោក កងទ័ពជើងអាកាស និងកងទ័ពជើងទឹក ដែលជាកម្លាំងសម្រាប់ប្រើប្រាស់ប្រតិបត្តិការសឹក ។

-អង្គទី ២ : ប្រមូលផ្តុំយោធិនដែលបម្រើការនៅក្នុងសេវារដ្ឋបាលរបស់កងទ័ព ។

អង្គធំៗទាំងពីរនេះ អាចត្រូវបំបែកចេញជាប្រភេទកងទ័ពឬឯកទេសជំនាញ ។

មាត្រា ៧.-

ការផ្លាស់ប្តូរប្រភេទកងទ័ពឬឯកទេសជំនាញរបស់យោធិន ត្រូវកំណត់ដោយអនុក្រឹត្យ ឬដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា ៨.-

ការតម្លើងឋានន្តរសក្តិត្រូវប្រព្រឹត្តទៅតាមលំដាប់មួយសក្តិម្តងៗហើយពុំអាចមានការតែងតាំងជាងារកិត្តិយសឡើយ ។

# ជំពូកទី ២

## សិទ្ធិ ភារកិច្ចនិងភារកិច្ចទទួលខុសត្រូវ

មាត្រា ៩.-

យោធិនមានសិទ្ធិនិងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត ។ ក៏ប៉ុន្តែការប្រើសិទ្ធិនិងសេរីភាពខ្លះ ត្រូវមានកម្រិតស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់នេះ ។

យោធិនត្រូវមានអព្យាក្រឹតភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារនិងហាមឃាត់ការប្រើមុខងារនិងប្រើប្រាស់សម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាពនយោបាយណាមួយ ។

មាត្រា ១០.-

យោធិនម្នាក់ៗអាចមានគំនិតឬជំនឿដែលមានលក្ខណៈជាទស្សនវិជ្ជាឬនយោបាយផ្ទាល់ខ្លួនបាន ប៉ុន្តែពុំអាចសំដែងជាសាធារណៈបានឡើយ។ វិធាននេះមិនហាមឃាត់ដល់ការប្រតិបត្តិដោយសេរីនូវជំនឿសាសនានៅក្នុងបរិវេណយោធានិងនៅលើនាវានៃកងទ័ពជើងទឹកឡើយ ។

យោធិនដែលចង់បកស្រាយជាសាធារណៈ ជាអាទិ៍ការសរសេរ ការធ្វើសន្និសីទ ឬសេចក្តីថ្លែងការណ៍នូវបញ្ហានយោបាយ ការសម្ងាត់យោធាឬការចោទប្រកាន់ជនបរទេសឬអង្គការអន្តរជាតិណាមួយ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា ១១.-

ការបញ្ចូលមកក្នុងបរិវេណឬគ្រឹះស្ថានយោធា ក៏ដូចជានៅក្នុងនាវានៃកងទ័ពជើងទឹកនូវការផ្សព្វផ្សាយ ទោះមានរូបភាពបែបណាក៏ដោយ ដែលនាំឱ្យខូចដល់ទឹកចិត្តឬវិន័យ ត្រូវហាមឃាត់ទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងដោយបទវិន័យទូទៅនៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ១២.-

យោធិនពុំអាចនាំគ្នាបង្កើតជាក្រុមវិជ្ជាជីវៈ ដែលមានលក្ខណៈជាសហជីពឬចូលរួមជាសមាជិកក្រុមវិជ្ជាជីវៈណាមួយ ដែលមិនសមស្របទៅនឹងវិន័យយោធាបានឡើយ ។

យោធិនអាចចូលជាសមាជិកដោយសេរីទៅក្នុងការប្រមូលផ្តុំជាក្រុម ដែលមិនបានចែងក្នុងកឋាខ័ណ្ឌទី ១ នៃមាត្រានេះ ។ ក៏ប៉ុន្តែការទទួលនាទីនៅក្នុងក្រុមឬសមាគមត្រូវមានការអនុញ្ញាតពីអាជ្ញាធរយោធាមានសមត្ថកិច្ចជាមុនសិន ។

រដ្ឋមន្ត្រីក្រសួងការពារជាតិតម្រូវឱ្យសាមីខ្លួនបោះបង់ចោលតួនាទីទទួលខុសត្រូវទាំងនោះ និងក្នុងករណីចាំបាច់ឱ្យលាលែងចេញផុតពីក្រុមតែម្តង ។

ដោយឡែកចំពោះអ្នកដែលត្រូវបំពេញកាតព្វកិច្ចការពារមាតុភូមិជាយោធិន ដែលពីមុនជាសមាជិកនៃអង្គការនយោបាយ ឬសហជីពណាមួយរួចមកហើយ សាមីខ្លួនអាចនៅជាសមាជិកនៃអង្គការឬសហជីពនោះតទៅទៀតបាន ប៉ុន្តែត្រូវផ្អាកគ្រប់សកម្មភាពនយោបាយឬសកម្មភាពសហជីពនៅក្នុងអំឡុងពេលដែលខ្លួនកំពុងបម្រើក្នុងកងយោធពលខេមរភូមិន្ទ ។

មាត្រា ១៣.-

ភាពជាយោធិន ការប្រើសិទ្ធិធ្វើកូដកម្មឬបាតុកម្មត្រូវហាមឃាត់ ។

មាត្រា ១៤.-

យោធិនត្រូវទទួលបញ្ជាទៅបម្រើការងារនៅគ្រប់កាលៈទេសៈ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ បើសិនជាការចាត់តាំងនោះបណ្តាលឱ្យមានការលំបាក ដែលចាំបាច់ត្រូវការឧបត្ថម្ភអាជ្ញាធរយោធាមានសមត្ថកិច្ចត្រូវបានផ្តល់ឱ្យទៅតាមប្រភេទនៃការលំបាកនោះ ។

មាត្រា ១៥.-

យោធិនមានសិទ្ធិសុំច្បាប់ឈប់សម្រាកដោយមានបៀវត្ស ។ រយៈពេលនិងបែបបទអនុញ្ញាតច្បាប់ ត្រូវកំណត់ដោយបទវិន័យទូទៅក្នុងកងយោធពលខេមរភូមិន្ទ ។

ពេលចាំបាច់ អាជ្ញាធរយោធាអាចកោះហៅជាបន្ទាន់នូវយោធិនដែលកំពុងឈប់សម្រាកច្បាប់ឱ្យចូលខ្លួនមកវិញ ។

មាត្រា ១៦.-

យោធិនអាចរៀបអាពាហ៍ពិពាហ៍បានដោយសេរី ។ ប៉ុន្តែត្រូវសុំការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិជាមុនសិន បើអនាគតសហព័ទ្ធពុំមានសញ្ជាតិជាខ្មែរ។

**មាត្រា ១៧.-**

យោធិនត្រូវគោរពនិងអនុវត្តរាល់បញ្ជាដោយមានស្មារតីទទួលខុសត្រូវ ។ បញ្ជាណាដែលមានភាពច្បាស់ក្រឡែតផ្ទុយពីច្បាប់ឬផ្ទុយពីអនុសញ្ញាអន្តរជាតិត្រូវហាមឃាត់ ។ ក្នុងករណីនេះ អ្នកបញ្ជាក្តី អ្នកអនុវត្តក្តី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

**មាត្រា ១៨.-**

ក្នុងករណីដែលមានពាក្យបណ្តឹងពីតតិយជនចំពោះយោធិន អំពីកំហុសក្នុងការបម្រើសេវា ដែលមិនមែនជាកំហុសផ្ទាល់ខ្លួនរបស់យោធិន រដ្ឋត្រូវការពារយោធិនឱ្យបានរួចចំពោះការផ្តន្ទាទោសផ្នែករដ្ឋប្បវេណី ។

យោធិនបំពេញភារកិច្ចដែលមានការគំរាមកំហែងឬវាយប្រហារដោយប្រការណាមួយពីសំណាក់ជនណាម្នាក់ដែលមិនមែនជាកំហុសផ្ទាល់ខ្លួន ត្រូវបានរដ្ឋទទួលការពារ ទទួលសងម្ហូវការខូចខាតនិងចេញមុខប្តឹងទៅតុលាការ ។

**មាត្រា ១៩.-**

យោធិនដែលជាអ្នកកាន់កាប់គ្រប់គ្រងមូលនិធិ សម្ភារៈបរិក្ខារឬស្បៀង ហើយធ្វើឱ្យខូចខាតបាត់បង់ឬយោធិនណាដែលគ្មានភារកិច្ច ហើយបានបង្កឱ្យមានការបំផ្លិចបំផ្លាញ ការបាត់បង់ឬការខូចខាតនូវយោធបរិក្ខារឬសម្ភារៈគ្រឿងបំពាក់ដែលបានប្រគល់ឱ្យ ត្រូវទទួលខុសត្រូវលើសំណង។ ក្នុងករណីធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

**មាត្រា ២០.-**

យោធិនត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់ អំពីហេតុការណ៍និងពត៌មានដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច បន្ថែមលើបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ដែលពាក់ព័ន្ធទៅនឹងការរំលោភលើកាតព្វកិច្ចរក្សាការសម្ងាត់យោធាឬការសម្ងាត់ខាងវិជ្ជាជីវៈ ។

ការបង្ហាញឬការផ្តល់ពត៌មាន លិខិតស្នាមឬឯកសារនៃសេវាផ្ទៃក្នុងឬបទបញ្ជាទៅឱ្យតតិយជន ត្រូវហាមឃាត់ ។

ក្រៅពីករណីដែលបានចែងច្បាស់លាស់ក្នុងច្បាប់ជាធរមាន យោធិនមិនអាចរួចពីកាតព្វកិច្ចរក្សាការសម្ងាត់ឬពីការហាមប្រាមដែលលើកឡើងក្នុងកថាខណ្ឌខាងលើនេះ លើកលែងតែបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

# ជំពូកទី ៣
## បៀវត្សនិងប្រាក់បំណាច់ផ្សេងៗ

**មាត្រា ២១.-**

យោធិនមានសិទ្ធិទទួលប្រាក់បៀវត្ស ដែលចំនួនទឹកប្រាក់កំណត់ទៅតាមឋានន្តរសក្តិ លំដាប់ថ្នាក់ គុណវុឌ្ឍិ ងារ តំណែងនិងអតីតភាព ។

យោធិនអាចទទួលនូវប្រាក់បន្ថែមបំណាច់ពិសេស ផ្តល់ជូនទៅតាមប្រភេទមុខងារ ដែលខ្លួនបំពេញឬហានិភ័យដែលអាចកើតឡើង ។

**មាត្រា ២២.-**

យោធិនត្រូវបានទទួលរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារ ដែលបានកំណត់ក្នុងច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២៣.-**

យោធិន អតីតយោធិនអាជីពនិងគ្រួសារផ្ទាល់របស់គេ មានសិទ្ធិព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យនៃកងយោធពលខេមរភូមិន្ទ ។

# ជំពូកទី ៤
## យោធិនអាជីព

**មាត្រា ២៤.-**

យោធិនអាជីព គឺជានាយទាហាន នាយទាហានរងឬពលទាហានដែលមានកម្ម ដែលត្រូវបានទទួលឱ្យចូលជាយោធិនអាជីព ក្រោយពីបានធ្វើពាក្យសុំចូល ហើយបានតែងតាំងឋានន្តរសក្តិតាមបទានុក្រម ។

## មាត្រា ២៥.-

យោធិនអាជីព ត្រូវហាមដាច់ខាត :

-មិនឱ្យយកម៉ោងរដ្ឋបាលទៅប្រកបវិជ្ជាជីវៈជាឯកជន

-មិនឱ្យយកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយឬដើម្បីសំឡុតគំរាមកំហែង បំពានសិទ្ធិពលរដ្ឋ

-មិនឱ្យប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្ដីថ្លៃថ្នូរនៃកងយោធពលខេមរភូមិន្ទ

-មិនឱ្យចូលជាសមាជិកនៃក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនជាលក្ខណៈឯកជន ។

## មាត្រា ២៦.-

យោធិនអាជីពត្រូវបានទទួលពិន្ទុមួយឆ្នាំម្ដង ។ មេបញ្ជាការផ្ទាល់ជាអ្នកដាក់ពិន្ទុនិងមូលវិចារណ៍ ត្រូវជូនដំណឹងអំពីមូលវិចារណ៍ចំពោះយោធិនអាជីពម្នាក់ៗឱ្យបានដឹងជារៀងរាល់ឆ្នាំ។

## មាត្រា ២៧.-

យោធិនអាជីពម្នាក់ៗ ត្រូវមានសំណុំឯកសារផ្ទាល់ខ្លួន :

-លិខិតស្នាមទាក់ទងនឹងស្ថានភាពរដ្ឋបាល

-លិខិតស្នាមនិងឯកសារផ្សេងៗដែលទាក់ទងនឹងសេចក្ដីសម្រេចនិងប្រកាសដែលមានលក្ខណៈស្របតាមលក្ខន្តិកៈឬបទវិន័យ

-ព្រឹត្តបត្រពិន្ទុ

ក្នុងសំណុំលិខិតនេះ មិនត្រូវមានឯកសារនិយាយអំពីមតិយោបល់ឬជំនឿក្នុងផ្លូវទស្សនវិជ្ជានិងនយោបាយនៃសាមីជនទេ ។

ឯកសារនីមួយៗត្រូវមានលេខរៀងនិងចុះបញ្ជីកា ។

## មាត្រា ២៨.-

អាចត្រូវតែងតាំងជានាយទាហានអាជីពបាន ចំពោះជនណាដែល :

-មានសញ្ជាតិខ្មែរ

-មានលិខិតថ្កោលទោសដែលបញ្ជាក់ថាគ្មានទោស

-មានសម្បទាតាមតម្រូវការ ដើម្បីបំពេញមុខងារ ។

មាត្រា ២៩.-

ការជ្រើសរើសនាយទាហានអាជីព ប្រព្រឹត្តទៅតាមការចូលសាលានាយទាហាន ដែលជ្រើសរើសយកបេក្ខជនឱ្យចូលសិក្សាជាសិស្សនាយទាហាន ដោយការប្រឡងប្រជែងក្នុងចំណោមនិស្សិតនិងដោយការប្រឡងប្រជែងក្នុងចំណោមយោធិន ។

ល័ក្ខខ័ណ្ឌនៃការជ្រើសរើសនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ។

មាត្រា ៣០.-

ការតម្លើងឋានន្តរសក្តិនៃនាយទាហានអាជីពត្រូវគិតទៅតាមរយៈពេលបម្រើការងារកន្លងមក ។ នាយទាហានអាជីពទាំងនោះត្រូវមានឈ្មោះក្នុងបញ្ជីអតីតភាព ដែលរៀបចំឡើងតាមលំដាប់សក្តិនិងតាមអង្គរបស់ខ្លួនទៅតាមអតីតភាពនៃនាយទាហានទាំងនោះ ។

មាត្រា ៣១.-

ការតម្លើងឋានន្តរសក្តិតាមជម្រើសឬតាមអតីតភាពមិនអាចធ្វើបាន បើសិនជាយោធិនមិនបានបម្រើគ្រប់រយៈពេលនិងកាន់កាប់មុខនាទីទទួលខុសត្រូវបញ្ជាការដូចកំណត់ខាងក្រោមនេះ:

| | រយៈពេលបម្រើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន | |
|---|---|---|
| ឋានន្តរសក្តិ | យោធិនជាកម្លាំងសម្រាប់ប្រើប្រាស់ប្រតិបត្តិការសឹក | យោធិនបម្រើក្នុងរសេវារដ្ឋបាល |
| វរសេនីយ៍ឯក<br>វរនាវីឯក | ៣ឆ្នាំ | ៤ឆ្នាំ |
| វរសេនីយ៍ទោ<br>វរនាវីទោ | ៥ឆ្នាំ | ៥ឆ្នាំ |
| វរសេនីយ៍ត្រី<br>វរនាវីត្រី | ៤ឆ្នាំ | ៥ឆ្នាំ |
| អនុសេនីយ៍ឯក<br>អនុនាវីឯក | ៦ឆ្នាំ | ៦ឆ្នាំ |

| | | |
|---|---|---|
| អនុសេនីយ៍ទោ<br>អនុនាវីទោ | ៤ឆ្នាំ | ៥ឆ្នាំ |
| អនុសេនីយ៍ត្រី<br>អនុនាវីត្រី | ២ឆ្នាំ | ២ឆ្នាំ |
| នាយចំណង់<br>នាយនាវីចំណង់ | ១ឆ្នាំ | ១ឆ្នាំ |

រយៈពេលសម្រាប់តម្លើងឋានន្តរសក្តិអាចខ្លីជាងរយៈពេលដែលកំណត់ខាងលើ ក្នុងកាលៈទេសៈចាំបាច់ដែលកំណត់ដោយអនុក្រឹត្យ ។

ចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ ការតម្លើងឋានន្តរសក្តិមិនអាចធ្វើតាមបទប្បញ្ញត្តិខាងលើទេ គឺអាចធ្វើតាមតម្រូវការរបស់កងយោធពលខេមរភូមិន្ទ ។

ចំពោះយោធិនដែលពលី មរណៈក្នុងពេលបេសកកម្ម ត្រូវបានតម្លើងឋានន្តរសក្តិជាកិត្តិយសបច្ឆាមរណៈ ។

**មាត្រា ៣២.-**

ការតម្លើងឋានន្តរសក្តិរបស់នាយទាហានអាជីពតាមអតីតភាព ប្រព្រឹត្តឡើងនៅក្នុងអង្គនីមួយៗតាមលំដាប់នៃបញ្ជីអតីតភាព ។

ពុំអាចត្រូវបានតម្លើងឋានន្តរសក្តិតាមជម្រើស ក្នុងករណីពុំមានឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិដែលត្រូវរៀបរៀងឡើងក្នុងមួយឆ្នាំម្តង ។

គណៈកម្មការមួយត្រូវបានតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងការពារជាតិមានភារកិច្ចរាយការណ៍ជូនរដ្ឋមន្ត្រីនូវមូលវិចារណ៍ចាំបាច់និងពិន្ទុដែលផ្តល់ឱ្យដោយបញ្ជាការតាមជាន់ថ្នាក់របស់សាមីយោធិន ។

ក្នុងករណីដែលមិនអាចជាប់ឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិប្រចាំឆ្នាំទេ សាមីយោធិនត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេបង្អស់តាមលេខរៀងនៅក្នុងតារាងតម្លើងឋានន្តរសក្តិឆ្នាំបន្ទាប់ លើកលែងតែគណៈកម្មការសម្រេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផលពីបញ្ជាការគ្រប់គ្រងសាមីយោធិន ។

មាត្រា ៣៣.-

ការតែងតាំងនិងការតម្លើងឋានន្តរសក្តិត្រូវសម្រេច ៖

-ដោយព្រះរាជក្រឹត្យសម្រាប់ថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវី

-ដោយអនុក្រឹត្យសម្រាប់នាយទាហានថ្នាក់វរសេនីយ៍ឯកនិងវរនាវីឯក

-ដោយប្រកាសរបស់ក្រសួងការពារជាតិសម្រាប់នាយទាហានចាប់ពីថ្នាក់វរសេនីយ៍ទោនិងវរនាវីទោចុះ ។

មាត្រា ៣៤.-

អាចត្រូវបានតែងតាំងជានាយទាហានរងអាជីព ចំពោះជនណា ៖

-មានសញ្ជាតិខ្មែរ

-ចូលបម្រើតាមកិច្ចសន្យា

-បានចូលបម្រើការរយៈពេលយ៉ាងតិច ៤ឆ្នាំ នៅក្នុងកងយោធពលខេមរភូមិន្ទ ហើយមានឋានន្តរសក្តិជានាយទាហានរងស្រាប់

-មានសម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ

ការចូលជានាយទាហានរងអាជីពត្រូវសម្រេចដោយប្រកាសរបស់ក្រសួងការពារជាតិ។

មាត្រា ៣៥.-

អតីតភាពនៃនាយទាហានរងអាជីពត្រូវគិតចាប់តាំងពីថ្ងៃចូលបម្រើការងារយោធាកន្លងមក ។

មាត្រា ៣៦.-

ការតម្លើងឋានន្តរសក្តិនាយទាហានរងអាជីព ប្រព្រឹត្តទៅតាមជម្រើស តាមអតីតភាព និងសមស្របទៅតាមសមាមាត្រ។ ល័ក្ខខ័ណ្ឌនេះនឹងកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ។ ការតម្លើងឋានន្តរសក្តិតាមអតីតភាពនៃនាយទាហានរងអាជីពត្រូវគិតទៅតាមអតីតភាពរបស់សាមីយោធិននៅក្នុងអង្គនីមួយៗ ហើយនិងទៅតាមប្រភេទកងទ័ពឬជំនាញឯកទេស ។

ពុំអាចត្រូវបានតម្លើងឋានន្តរសក្តិបានទេ ក្នុងករណីមិនបានគ្រប់រយៈពេលអប្បបរមាបម្រើការងារដូចបង្ហាញក្នុងតារាងខាងក្រោមនេះ ៖

| ឋានន្តរសក្តិ | រយៈពេលបម្រើការក្នុងឋានន្តរសក្តិមួយថ្នាក់ ដើម្បីអាចតម្លើងបាន | |
|---|---|---|
| | យោធិនជាកម្លាំងសម្រាប់ប្រើប្រាស់ប្រតិបត្តិការសឹក | យោធិនបម្រើក្នុងសេវារដ្ឋបាល |
| ព្រឹន្ទបាលឯក<br>នាយចក្របាលឯក | ៣ឆ្នាំ | ៤ឆ្នាំ |
| ព្រឹន្ទបាលទោ<br>នាយចក្របាលទោ | ៣ឆ្នាំ | ៤ឆ្នាំ |
| ពលបាលឯក<br>ចក្របាលឯក | ២ឆ្នាំ | ៣ឆ្នាំ |
| ពលបាលទោ<br>ចក្របាលទោ | ២ឆ្នាំ | ៣ឆ្នាំ |
| ពលបាលត្រី<br>ចក្របាលត្រី | ២ឆ្នាំ | ៣ឆ្នាំ |

ពុំអាចជាកម្មវត្ថុនៃការតម្លើងឋានន្តរសក្តិតាមជម្រើស ក្នុងករណីសាមីយោធិនពុំមានឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិ ដែលរៀបរៀងឡើងមួយឆ្នាំម្តង តាមអង្គនិងជួនកាលតាមប្រភេទកងទ័ពឬជំនាញឯកទេស ។

ពុំអាចត្រូវបានតម្លើងឋានន្តរសក្តិ ក្នុងករណីមិនទាន់បានបំពេញរយៈពេលអប្បបរមានៅក្នុងឋានន្តរសក្តិទាបដែលកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ លើកលែងតែអ្នកមានស្នាដៃវិសេសវិសាល ។

គណៈកម្មការមួយត្រូវបានតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងការពារជាតិឬអាជ្ញាធរដែលបានផ្ទេរសិទ្ធិពីរដ្ឋមន្ត្រី មានភារកិច្ចរាយការណ៍ជូនរដ្ឋមន្ត្រីនូវមូលវិចារណ៍ចាំបាច់និងពិន្ទុដែលផ្តល់ឱ្យបេក្ខជនដោយបញ្ជាការតាមជាន់ថ្នាក់របស់គេ ។

ម្យ៉ាងទៀត បើមានតម្រូវការចាំបាច់ រយៈពេលសម្រាប់តម្លើងឋានន្តរសក្តិ អាចខ្លីជាងរយៈពេលដែលកំណត់ខាងលើ ។

ចំពោះនាយទាហានរងអាជីព ដែលពលីមរណៈក្នុងពេលបេសកកម្មត្រូវបានតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ ។

ក្នុងករណីដែលមិនអាចដាប់ឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិប្រចាំឆ្នាំ សាមីយោធិនត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេបង្អស់តាមលេខរៀងនៅក្នុងតារាងតម្លើងឋានន្តរសក្តិឆ្នាំបន្ទាប់ លើកលែងតែគណៈកម្មការសម្រេចផ្សេងពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផលពីបញ្ជាការគ្រប់គ្រងសាមីយោធិន ។

ការតែងតាំងនិងតម្លើងឋានន្តរសក្តិត្រូវសម្រេចដោយប្រកាសរបស់ក្រសួងការពារជាតិ។

**មាត្រា ៣៧.-**

គុណប្រយោជន៍នៃនាយទាហានរងអាជីព ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## ស្ថានភាពយោធិនអាជីព

**មាត្រា ៣៨.-**

យោធិនអាជីពគ្រប់រូប ត្រូវបានដាក់នៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១-ស្ថានភាពសកម្មគឺជាស្ថានភាពដែលយោធិនអាជីពកាន់កាប់មុខតំណែងតាមឋានន្តរសក្តិរបស់ខ្លួន ។

២-ស្ថានភាពអសកម្មគឺជាស្ថានភាពបណ្តោះអាសន្នរបស់យោធិនអាជីពដែលមិនអាចកាន់កាប់មុខតំណែងតាមឋានន្តរសក្តិរបស់ខ្លួន ក្នុងរយៈពេលលើសពី ៦ខែ ឡើងទៅ ដោយសារហេតុផលផ្សេងៗ ។

៣-ស្ថានភាពក្រៅតំណែងគឺជាស្ថានភាពរបស់យោធិនអាជីពដែលត្រូវបានដាក់មួយរយៈឱ្យនៅក្រៅអង្គភាពដើមរបស់ខ្លួន ដើម្បីបំពេញមុខងារសាធារណៈណាមួយផ្សេងក្នុងរដ្ឋបាលស៊ីវិលឬមុខងារឯកជនណាមួយផ្សេងដែលជាផលប្រយោជន៍សាធារណៈ ។

៤-ស្ថានភាពចូលនិវត្តន៍គឺជាស្ថានភាពរបស់យោធិនអាជីពដែលមានអាយុត្រូវចូលនិវត្តន៍ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

៥-ស្ថានភាពក្រៅក្របខ័ណ្ឌគឺជាស្ថានភាពរបស់យោធិនអាចដែលអាចដល់កំណត់ពេលចូលនិវត្តន៍បាន អនុលោមតាមចំណុច ៤នៃមាត្រានេះ តែត្រូវបានអនុញ្ញាតឱ្យបម្រើការងារបន្តទៀតនៅក្នុងសេវា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កងយោធពលខេមរភូមិន្ទនិងសំណូមពរសាមីយោធិនផង ។

**មាត្រា ៣៩.-**

បែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពដែលមានចែងក្នុងចំណុច ១.២. ៣. ៤ .៥ នៃមាត្រា ៣៨ ព្រមទាំងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤០.-**

ភាពយោធានឹងបាត់បង់ ក្នុងករណីដែលយោធិនបានសុំលាលែងពីជួរទ័ពដោយមានការព្រមព្រៀងពីអាជ្ញាធរសមត្ថកិច្ច ឬក្នុងករណីដែលយោធិនបានចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ឬក្នុងករណីដែលយោធិនបានបាត់បង់ឋានន្តរសក្តិតាមសាលក្រមតុលាការ ។

យោធិនដែលបានបញ្ចប់ភាពយោធាដូចបានចែងក្នុងចំណុច ៤ នៃមាត្រា ៣៨ ត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌយោធាបម្រុង ហើយរក្សាឋានន្តរសក្តិដែលសាមីយោធិនមានស្រាប់។

ចំពោះយោធិនដែលតុលាការបានផ្តន្ទាទោស មិនត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌយោធាបម្រុងបានទេ ។

## ជំពូកទី ៦

## យោធិនជាប់កិច្ចសន្យា

**មាត្រា ៤១.-**

យោធិនជាប់កិច្ចសន្យាគឺជាអ្នកចូលបម្រើការងារដោយស្ម័គ្រចិត្តតាមកិច្ចសន្យា នៅក្នុងឋានន្តរសក្តិជាពលទាហាននិងជានាយទាហានរងនៅក្នុងកងយោធពលខេមរភូមិន្ទសម្រាប់ :

-មួយរយៈពេលដែលបានកំណត់

-ពេលមានសង្គ្រាមទាំងមូលឬមួយរយៈ

ចំនួននិងល័ក្ខខ័ណ្ឌនៃការជ្រើសរើស ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤២.-**

យោធិនជាប់កិច្ចសន្យាត្រូវបានជ្រើសរើសចំពោះជនណាដែល :

-មានសញ្ជាតិខ្មែរ លើកលែងតែក្នុងពេលមានសង្គ្រាម

-មានអាយុគ្រប់ ១៨ឆ្នាំ

-មានសម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ ។

**មាត្រា ៤៣.-**

ចំពោះយោធិនកំពុងជាប់កិច្ចសន្យាអាចសុំបន្តកិច្ចសន្យាបាន ចាប់ពីថ្ងៃចប់កិច្ចសន្យាមុន ។

**មាត្រា ៤៤.-**

ឋានន្តរសក្តិ ស្ថានភាពបាត់បង់សុខភាព សមត្ថភាពការងារ ការហ្វឹកហ្វឺនវិជ្ជាជីវៈព្រមទាំងគុណប្រយោជន៍ចំពោះយោធិនជាប់កិច្ចសន្យា ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧

## ទណ្ឌកម្ម

**មាត្រា ៤៥.-**

យោធិន ក្នុងករណីមានកំហុសត្រូវទទួលទណ្ឌកម្មយោធាដោយមិនគិតពីការផ្តន្ទាទោសតាមផ្លូវតុលាការ :

១-ទណ្ឌកម្មខាងផ្នែកវិន័យដែលកំណត់ដោយបទវិន័យទូទៅក្នុងកងយោធពលខេមរភូមិន្ទ ។

២-ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅដែលមានរៀបរាប់នៅក្នុងមាត្រា៤៨.៤៩.៥០.៥១នៃច្បាប់នេះ ។

**មាត្រា ៤៦.-**

មុននឹងដាក់ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅ ត្រូវសុំយោបល់ក្រុមប្រឹក្សាវិន័យជាមុនសិន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវិន័យត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា ៤៧.-

ក្រោយពីបានទទួលយោបល់ពីក្រុមប្រឹក្សាវិន័យ រដ្ឋមន្ត្រីក្រសួងការពារជាតិឬអាជ្ញាធរមានសមត្ថកិច្ចក្នុងរឿងនេះ អាចសម្រេចដាក់ទណ្ឌកម្មដែលមានចែងក្នុងមាត្រា ៤៥នៃច្បាប់នេះ ។

ការដាក់ទណ្ឌកម្មខាងផ្នែកវិន័យនិងទណ្ឌកម្មតាមលក្ខន្តិកៈទូទៅ អាចសម្រេចដាក់ទាំងពីរបាន ។

**មាត្រា ៤៨.-**

ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅអនុវត្តចំពោះយោធិនអាជីពមាន :

-ការលុបឈ្មោះចេញពីតារាងតម្លើងឋានន្តរសក្តិ

-ការដកហូតមុខតំណែង ដោយដាក់ឱ្យនៅក្នុងស្ថានភាពអសកម្ម

-ការលុបឈ្មោះចេញពីក្របខ័ណ្ឌ

-ការល្បួរមុខតំណែង

**មាត្រា ៤៩.-**

ការដកហូតមុខតំណែងដោយដាក់ឱ្យនៅក្នុងស្ថានភាពអសកម្មតាមបទប្បញ្ញត្តិក្នុងចំណុច ២ នៃមាត្រា ៣៨ ត្រូវអនុវត្តចំពោះតែយោធិនដែលមិនមានសិទ្ធិចូលនិវត្តន៍ភ្លាមៗ។ ការដកហូតមុខតំណែងមិនអាចមានរយៈពេលលើសពី ៣ឆ្នាំ ឡើយ ។

នៅពេលផុតកំណត់នៃរយៈពេលដែលស្ថិតនៅក្នុងស្ថានភាពអសកម្ម យោធិនត្រូវដាក់ឱ្យនៅក្នុងស្ថានភាពសកម្មវិញ ។

រយៈពេលអសកម្មដោយការដកហូតតំណែង មិនត្រូវយកមកគិតក្នុងការតម្លើងឋានន្តរសក្តិនិងសម្រាប់ចូលនិវត្តន៍ទេ។ នៅក្នុងស្ថានភាពនេះ យោធិនលែងមានឈ្មោះនៅក្នុងបញ្ជីអតីតភាព ហើយមានសិទ្ធិទទួលតែ ៤៥ % ( សែសិបប្រាំភាគរយ ) នៃប្រាក់បៀវត្សឋានន្តរសក្តិ ។

**មាត្រា ៥០.-**

ការលុបឈ្មោះយោធិនអាជីពចេញពីក្របខ័ណ្ឌអាចអនុវត្តបាន ដោយមិនគិតពីរយៈពេលដែលបានបម្រើការងារ ។

**មាត្រា ៥១.-**

ក្នុងករណីមានកំហុសធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងដោយយោធិនអាជីព យោធិនរូបនោះអាចត្រូវល្បួរមុខតំណែងជាបន្ទាន់ដោយអាជ្ញាធរមានសមត្ថកិច្ចដាក់វិន័យ ។

ក្នុងករណីខាងលើនេះ រដ្ឋមន្ត្រីក្រសួងការពារជាតិមានសិទ្ធិកំណត់ចំនួនប្រាក់សល្យ៉ូយដែលត្រូវកាត់ទុក ។ ប្រាក់សល្យ៉ូយនេះមិនត្រូវលើសពីពាក់កណ្តាលនៃប្រាក់បៀវត្ស ឋានន្តរសក្តិរបស់សាមីយោធិនឡើយ ។

ស្ថានភាពដែលយោធិនព្យួរមុខតំណែង ត្រូវតែដោះស្រាយជាស្ថាពរនៅក្នុងរយៈពេល ៤ខែ គិតពីថ្ងៃដែលសេចក្តីសម្រេចព្យួរមុខតំណែងចូលជាធរមាន។ កាលណាពុំមានសេចក្តីសម្រេចណាមួយត្រូវធ្វើឡើងនៅពេលបញ្ចប់រយៈពេលនេះ សាមីយោធិនត្រូវបានទទួលសាជាថ្មីនូវបៀវត្សគ្រប់ចំនួន លើកលែងតែយោធិននោះជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ។

ក្នុងករណីយោធិនដែលត្រូវព្យួរមុខតំណែងមិនទទួលរងនូវទណ្ឌកម្មណាមួយតាមលក្ខន្តិកៈនេះទេ ឬបើនៅពេលបញ្ចប់ក្នុងរយៈពេលដូចមានចែងក្នុងកថាខ័ណ្ឌខាងលើ ហើយបើគ្មានសេចក្តីសម្រេចណាមួយចំពោះយោធិនរូបនេះទេ យោធិននោះ មានសិទ្ធិទាមទារយកសំណងប្រាក់សល្យ៉ូយដែលបានកាត់យកពីបៀវត្សរបស់ខ្លួន ។

ក្នុងករណីនៃបណ្តឹងអាជ្ញា សិទ្ធិទទួលបៀវត្សត្រូវបានបញ្ឈប់តែនៅក្រោយពេលដែលមានសាលក្រមរបស់សាលាជំរះក្តីត្រូវបានចាត់ទុកជាស្ថាពរ ។

# ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៥២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ហត្ថលេខា | ហត្ថលេខា |
| អ៊ឹង ហួត | ហ៊ុន សែន |

បានជំរាបជូន

ឯកឧត្តម នាយករដ្ឋមន្ត្រីទី១ និង

សម្តេច នាយករដ្ឋមន្ត្រីទី២

រដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់ ទា ចំរាត់

លេខ : ៤៥៦ ចល

ដើម្បីចំលងចែក

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល